# សន្លឹកឆ្នោតផ្លូវការ



**ខោនធី SAN JOAQUIN**
**ការបោះឆ្នោតទូទៅ**
**ថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2026**

Khmer BT 77

## សេចក្ដីណែនាំសម្រាប់ការបោះឆ្នោត

**ត្រូវប្រាកដថា សន្លឹកឆ្នោតរបស់អ្នកបានការ**

- ប្រើតែបិចទឹកពណ៌ខៀវ ឬពណ៌ខ្មៅប៉ុណ្ណោះ ។

- អ្នកអាចបោះឆ្នោតលើការប្រកួតប្រជែងច្រើន ឬតិចតាមដែលអ្នកចង់បាន ។
- ដើម្បីបោះឆ្នោតជ្រើសរើសបេក្ខជន ឬវិធានការណាមួយ ត្រូវគូសបំពេញក្នុងប្រអប់នៅជាប់នឹងពាក្យ "គាំទ្រ" ឬ មិនគាំទ្រ" ឬឈ្មោះរបស់បេក្ខជន ។

**បេក្ខជនសរសេរឈ្មោះបញ្ចូល**

- ដើម្បីបោះឆ្នោតជូនបេក្ខជនសរសេរឈ្មោះបញ្ចូលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ សូមសរសេរឈ្មោះនៅក្នុងចន្លោះទទេដែលបានផ្តល់ជូន ហើយបំពេញប្រអប់ ។

**ការកែប្រែកំហុសនៅលើសន្លឹកឆ្នោតរបស់អ្នក**

- ប្រសិនបើអ្នកគូសប្រអប់ខុស សូមគូសឆ្លងលើប្រអប់គូសខុសដោយអចេតនា ហើយគូសប្រអប់ដែលអ្នកចង់បាន ឬស្នើសុំសន្លឹកឆ្នោតថ្មីមួយ ។




- កំហុសនៅក្នុងការប្រកួតប្រជែងមួយ មិនប៉ះពាល់ដល់ផ្នែកដែលនៅសល់នៃសន្លឹកឆ្នោតទេ

**ជៀសវាងការបោះឆ្នោតលើសកំណត់**

- កុំជ្រើសរើសបេក្ខជនលើសពីចំនួនដែលត្រូវជ្រើសតាំង ។

**តំណែងដែលត្រូវបានតែងតាំងដោយអ្នកបោះឆ្នោត និងមិនប្រកាន់បក្សពួក** បេក្ខជនបង្ហាញទំនោរចំពោះគណបក្សមួយ (ឬគ្មានទំនោរ) ដើម្បីជាព័ត៌មានដល់អ្នកបោះឆ្នោត ។ នេះមិនមែនជាចំណារ ឬការយល់ព្រមរបស់គណបក្សឡើយ ។

## រដ្ឋ

### អភិបាល

បោះឆ្នោតឱ្យបេក្ខជនម្នាក់

☐ **STEVE HILTON**
*ម្ចាស់អាជីវកម្មខ្នាតតូច*
*នោរចំពោះគណបក្ស ៖ គណបក្សសាធារណរដ្ឋ*

☐ **XAVIER BECERRA**
*មេធាវីសិទ្ធិបោះឆ្នោត*
*ទំនោរចំពោះគណបក្ស ៖ គណបក្សប្រជាធិបតេយ្យ*

### អភិបាលរង

បោះឆ្នោតឱ្យបេក្ខជនម្នាក់

☐ **GLORIA ROMERO**
*អ្នកអប់រំ/ស្ត្រីអ្នកជំនួញ*
*នោរចំពោះគណបក្ស ៖ គណបក្សសាធារណរដ្ឋ*

☐ **FIONA MA**
*ហិរញ្ញិករដ្ឋ/CPA*
*ទំនោរចំពោះគណបក្ស ៖ គណបក្សប្រជាធិបតេយ្យ*

### រដ្ឋលេខាធិការ

បោះឆ្នោតឱ្យបេក្ខជនម្នាក់

☐ **DONALD P. (DON) WAGNER**
*អភិបាលខោនធី Orange*
*នោរចំពោះគណបក្ស ៖ គណបក្សសាធារណរដ្ឋ*

☐ **SHIRLEY N. WEBER**
*រដ្ឋលេខាធិការនៃរដ្ឋ California*
*ទំនោរចំពោះគណបក្ស ៖ គណបក្សប្រជាធិបតេយ្យ*

### អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ

បោះឆ្នោតឱ្យបេក្ខជនម្នាក់

☐ **MALIA M. COHEN**
*អ្នកត្រួតពិនិត្យហិរញ្ញវត្ថុរដ្ឋ/ម្តាយ*
*ទំនោរចំពោះគណបក្ស ៖ គណបក្សប្រជាធិបតេយ្យ*

☐ **HERB W MORGAN**
*ប្រធានផ្នែកវិនិយោគ*
*នោរចំពោះគណបក្ស ៖ គណបក្សសាធារណរដ្ឋ*

### ហិរញ្ញិក

បោះឆ្នោតឱ្យបេក្ខជនម្នាក់

☐ **JENNIFER HAWKS**
*នាយកប្រតិបត្តិអាជីវកម្មចូលនិវត្តន៍*
*នោរចំពោះគណបក្ស ៖ គណបក្សសាធារណរដ្ឋ*

☐ **ELENI KOUNALAKIS**
*អភិបាលរងរដ្ឋ California*
*ទំនោរចំពោះគណបក្ស ៖ គណបក្សប្រជាធិបតេយ្យ*

### អគ្គរដ្ឋអាជ្ញា

បោះឆ្នោតឱ្យបេក្ខជនម្នាក់

☐ **ROB BONTA**
*អគ្គរដ្ឋអាជ្ញារដ្ឋ California*
*ទំនោរចំពោះគណបក្ស ៖ គណបក្សប្រជាធិបតេយ្យ*

☐ **MICHAEL E. GATES**
*អនុរដ្ឋអាជ្ញាសហរដ្ឋអាមេរិក*
*នោរចំពោះគណបក្ស ៖ គណបក្សសាធារណរដ្ឋ*

### ស្នងការធានារ៉ាប់រង

បោះឆ្នោតឱ្យបេក្ខជនម្នាក់

☐ **JANE KIM**
*មេធាវី/អ្នកតស៊ូមតិដើម្បីអ្នកប្រើប្រាស់*
*ទំនោរចំពោះគណបក្ស ៖ គណបក្សប្រជាធិបតេយ្យ*

☐ **BEN ALLEN**
*សមាជិកព្រឹទ្ធសភារដ្ឋ California*
*ទំនោរចំពោះគណបក្ស ៖ គណបក្សប្រជាធិបតេយ្យ*

### សមាជិក គណៈកម្មការសមភាពថ្នាក់រដ្ឋ មណ្ឌលទី 1

បោះឆ្នោតឱ្យបេក្ខជនម្នាក់

☐ **NELSON ESPARZA**
*គ្រូបង្រៀន/អ្នកសេដ្ឋកិច្ច/សមាជិកក្រុមប្រឹក្សា*
*ទំនោរចំពោះគណបក្ស ៖ គណបក្សប្រជាធិបតេយ្យ*

☐ **SHANNON GROVE**
*សមាជិកព្រឹទ្ធសភារដ្ឋ/ស្ត្រីអ្នកជំនួញ*
*នោរចំពោះគណបក្ស ៖ គណបក្សសាធារណរដ្ឋ*

## តំណាងសហរដ្ឋអាមេរិក

### មណ្ឌលសមាជ 13

បោះឆ្នោតឱ្យបេក្ខជនម្នាក់

☐ **ADAM GRAY**
*តំណាងសហរដ្ឋអាមេរិក/អ្នកអប់រំ*
*ទំនោរចំពោះគណបក្ស ៖ គណបក្សប្រជាធិបតេយ្យ*

☐ **KEVIN LINCOLN**
*ម្ចាស់អាជីវកម្មខ្នាតតូច*
*នោរចំពោះគណបក្ស ៖ គណបក្សសាធារណរដ្ឋ*

## សមាជិកសភាតំណាងរាស្ត្រថ្នាក់រដ្ឋ

### មណ្ឌលសភា 9

បោះឆ្នោតឱ្យបេក្ខជនម្នាក់

☐ **MATTHEW ADAMS**
*បុរសអ្នកជំនួញ/ឪពុក*
*ទំនោរចំពោះគណបក្ស ៖ គណបក្សប្រជាធិបតេយ្យ*

☐ **HEATH FLORA**
*សមាជិកសភារដ្ឋ*
*នោរចំពោះគណបក្ស ៖ គណបក្សសាធារណរដ្ឋ*

## តុលាការ

បោះឆ្នោតគាំទ្រ ឬមិនគាំទ្រសម្រាប់ការិយាល័យនីមួយ ។

### សម្រាប់ចៅក្រមរងនៃតុលាការកំពូល

តើចៅក្រមរងនៃតុលាការកំពូល **JOSHUA GROBAN** គឃ្លីត្រូវបោះឆ្នោតជ្រើសតាំងឲ្យចូលកាន់តំណែងសម្រាប់អាណត្តិដែលផ្តល់ដោយច្បាប់ដែរឬទេ?

☐ **គាំទ្រ**
☐ **មិនគាំទ្រ**

### សម្រាប់ចៅក្រមរងនៃតុលាការកំពូល

តើចៅក្រមរងនៃតុលាការកំពូល **KELLI M. EVANS** គឃ្លីត្រូវបោះឆ្នោតជ្រើសតាំងឲ្យចូលកាន់តំណែងសម្រាប់អាណត្តិដែលផ្តល់ដោយច្បាប់ដែរឬទេ?

☐ **គាំទ្រ**
☐ **មិនគាំទ្រ**

### សម្រាប់ប្រធានចៅក្រមរដ្ឋបាល នៃ សាលាឧទ្ធរណ៍ មណ្ឌលទីបី

តើប្រធានចៅក្រមរដ្ឋបាល **LAURIE EARL** គឃ្លីត្រូវបោះឆ្នោតជ្រើសតាំងឲ្យចូលកាន់តំណែងសម្រាប់អាណត្តិដែលផ្តល់ដោយច្បាប់ដែរឬទេ?

☐ **គាំទ្រ**
☐ **មិនគាំទ្រ**

### សម្រាប់ចៅក្រមរងនៃតុលាការឧទ្ធរណ៍ មណ្ឌលទីបី

តើចៅក្រមរង **LAURI DAMRELL** គឃ្លីត្រូវបោះឆ្នោតជ្រើសតាំងឲ្យចូលកាន់តំណែងសម្រាប់អាណត្តិដែលផ្តល់ដោយច្បាប់ដែរឬទេ?

☐ **គាំទ្រ**
☐ **មិនគាំទ្រ**

### សម្រាប់ចៅក្រមរងនៃតុលាការឧទ្ធរណ៍ មណ្ឌលទីបី

តើ **DAVID B. SAPP** គឃ្លីត្រូវបោះឆ្នោតជ្រើសតាំងឲ្យចូលកាន់តំណែងសម្រាប់អាណត្តិដែលផ្តល់ដោយច្បាប់ដែរឬទេ?

☐ **គាំទ្រ**
☐ **មិនគាំទ្រ**

### សម្រាប់ចៅក្រមរងនៃតុលាការឧទ្ធរណ៍ មណ្ឌលទីបី

តើចៅក្រមរង **STACY BOULWARE EURIE** គឃ្លីត្រូវបោះឆ្នោតជ្រើសតាំងឲ្យចូលកាន់តំណែងសម្រាប់អាណត្តិដែលផ្តល់ដោយច្បាប់ដែរឬទេ?

☐ **គាំទ្រ**
☐ **មិនគាំទ្រ**

### សម្រាប់ចៅក្រមរងនៃតុលាការឧទ្ធរណ៍ មណ្ឌលទីបី

តើចៅក្រមរង **JONATHAN RENNER** គឃ្លីត្រូវបោះឆ្នោតជ្រើសតាំងឲ្យចូលកាន់តំណែងសម្រាប់អាណត្តិដែលផ្តល់ដោយច្បាប់ដែរឬទេ?

☐ **គាំទ្រ**
☐ **មិនគាំទ្រ**

### សម្រាប់ចៅក្រមរងនៃតុលាការឧទ្ធរណ៍ មណ្ឌលទីបី

តើចៅក្រមរង **AIMEE A. FEINBERG** គឃ្លីត្រូវបោះឆ្នោតជ្រើសតាំងឲ្យចូលកាន់តំណែងសម្រាប់អាណត្តិដែលផ្តល់ដោយច្បាប់ដែរឬទេ?

☐ **គាំទ្រ**
☐ **មិនគាំទ្រ**

### សម្រាប់ចៅក្រមរងនៃតុលាការឧទ្ធរណ៍ មណ្ឌលទីបី

តើចៅក្រមរង **SHAMA MESIWALA** គឃ្លីត្រូវបោះឆ្នោតជ្រើសតាំងឲ្យចូលកាន់តំណែងសម្រាប់អាណត្តិដែលផ្តល់ដោយច្បាប់ដែរឬទេ?

☐ **គាំទ្រ**
☐ **មិនគាំទ្រ**

# សន្លឹកឆ្នោតផ្លូវការ

**ខោនធី SAN JOAQUIN**
**ការបោះឆ្នោតទូទៅ**
**ថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2026**

Khmer BT 77

## សាលារៀន

### អគ្គនាយកអប់រំសាធារណៈ

បោះឆ្នោតឱ្យបេក្ខជនម្នាក់

- [ ] **SONJA SHAW**
  *ប្រធានមណ្ឌលសិក្សាធិការ*
- [ ] **RICHARD BARRERA**
  *ទីប្រឹក្សាអគ្គនាយកថ្នាក់រដ្ឋ*
- [ ] _____
  *សរសេរឈ្មោះចូល*

## ទីក្រុង

### អភិបាលក្រុង Lathrop

បោះឆ្នោតឱ្យបេក្ខជនម្នាក់

- [ ] **PAUL AKINJO**
  *អភិបាលក្រុង Lathrop*
- [ ] **MINNIE "COTTON" DIALLO**
  *សមាជិកាក្រុមប្រឹក្សាទីក្រុង Lathrop*
- [ ] _____
  *សរសេរឈ្មោះចូល*

### សមាជិកក្រុមប្រឹក្សាទីក្រុង Lathrop

សូមបោះឆ្នោតឱ្យបេក្ខជនមិនលើសពីពីរនាក់

- [ ] **SHELITA JEFFERSON**
  *ភ្នាក់ងារអចលនទ្រព្យ/ម្តាយ*
- [ ] **STEVE DRESSER**
  *អ្នកកំពុងកាន់តំណែងដែលបានតែងតាំង*
- [ ] **LEANDRO VICUÑA**
  *នាយកប្រតិបត្តិធនាគារ/ឪពុក*
- [ ] **DANIEL MACNEILAGE**
  *ប្រធានការដ្ឋានសំណង់*
- [ ] _____
  *សរសេរឈ្មោះចូល*
- [ ] _____
  *សរសេរឈ្មោះចូល*

## វិធានការដែលបានដាក់ស្នើទៅអ្នកបោះឆ្នោត

## រដ្ឋ

### សំណើរ 1

**អនុញ្ញាតឱ្យចេញមូលបត្របំណុលសម្រាប់កម្មវិធីលំនៅឋានដែលមានតម្លៃសមរម្យ ។ លក្ខន្តិកៈច្បាប់ ។** អនុញ្ញាតឱ្យចេញមូលបត្របំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋចំនួន $11.25 ពាន់លាន សម្រាប់កម្មវិធីលំនៅឋានដែលមានតម្លៃសមរម្យ រួមមាន លំនៅឋានជួលពហុគ្រួសារ ប្រាក់កម្ចីទិញផ្ទះសម្រាប់អតីតយុទ្ធជន លំនៅឋានដែលមានការគាំទ្រ ការរក្សាទុកលំនៅឋានដែលមានតម្លៃសមរម្យដែលមានស្រាប់ និងជំនួយសម្រាប់ការបង់ប្រាក់កក់ដំបូង ។ **ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ៖** បង្កើនការចំណាយរបស់រដ្ឋចំនួន $500 លាន ដល់ $600 លាន ក្នុងមួយឆ្នាំ ប្រហែល 25 ឆ្នាំ ដើម្បីសងបំណុលមូលបត្របំណុលសម្រាប់លំនៅឋាន ។ **អ្នកគាំទ្រ ៖** US Vets; CA Federation of Teachers; Self-Help for the Elderly; Habitat for Humanity CA; CA Alliance of Child & Family Services **ភាគីប្រឆាំង ៖** មិនមានការដាក់ស្នើ

- [ ] **គាំទ្រ**
- [ ] **មិនគាំទ្រ**

### សំណើរ 2

**បង្កើនមូលនិធិបម្រុងសម្រាប់គ្រាអាសន្នរបស់រដ្ឋ ។ វិសោធនកម្មច្បាប់រដ្ឋធម្មនុញ្ញ ។** បង្កើនមូលនិធិបម្រុងសម្រាប់គ្រាអាសន្នរបស់រដ្ឋ California (Rainy Day Fund) ដែលត្រូវបានអនុម័តដោយអ្នកបោះឆ្នោតក្នុងឆ្នាំ 2014 ដើម្បីផ្តល់មូលនិធិសម្រាប់ការអប់រំ ការថែទាំសុខភាព សុវត្ថិភាពសាធារណៈ និងសេវាសំខាន់ៗផ្សេងទៀតក្នុងអំឡុងពេលសេដ្ឋកិច្ចធ្លាក់ចុះ ។ **ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ៖** ប្រាក់បម្រុងក្នុងថវិការដ្ឋនឹងកើនឡើង ។ **អ្នកគាំទ្រ ៖** CA Professional Firefighters; LA Chamber of Commerce; Gavin Newsom; Xavier Becerra; Assemblymember Jesse Gabriel **ភាគីប្រឆាំង ៖** មិនមានការដាក់ស្នើ

- [ ] **គាំទ្រ**
- [ ] **មិនគាំទ្រ**

### សំណើរ 3

**ផ្តល់មូលនិធិអចិន្ត្រៃយ៍សម្រាប់សាលារៀន និងការថែទាំសុខភាពដោយបន្តអនុវត្តពន្ធដែលមានស្រាប់លើប្រាក់ចំណូលខ្ពស់ ។ វិសោធនកម្មរដ្ឋធម្មនុញ្ញ ផ្តើមឡើងដោយប្រជាពលរដ្ឋ ។** ធ្វើឱ្យអត្រាពន្ធដែលមានស្រាប់ និងត្រូវបានអ្នកបោះឆ្នោតអនុម័ត ក្លាយជាអចិន្ត្រៃយ៍ សម្រាប់បុគ្គលដែលមានប្រាក់ចំណូលលើសពី $371,000 (កែតម្រូវជារៀងរាល់ឆ្នាំតាមអតិផរណា) ។ បែងចែកចំណូលពីពន្ធទៅឱ្យការអប់រំសាធារណៈ ។ **ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ៖** រក្សាចំណូលពន្ធលើប្រាក់ចំណូលរបស់រដ្ឋប្រចាំឆ្នាំចំនួន $5 ពាន់លាន ដល់ $15 ពាន់លាន ដោយធ្វើឱ្យការដំឡើងពន្ធបណ្តោះអាសន្នលើអ្នកមានប្រាក់ចំណូលខ្ពស់ ក្លាយជាអចិន្ត្រៃយ៍ ជំនួសឱ្យការឱ្យវាផុតកំណត់នៅឆ្នាំ 2031 ។ **អ្នកគាំទ្រ ៖** California Teachers Association; CA School Nurses Organization; California State PTA; Planned Parenthood Affiliates of CA **ភាគីប្រឆាំង ៖** California Taxpayers Association; Family Business Association of California; California Hispanic Chambers of Commerce

- [ ] **គាំទ្រ**
- [ ] **មិនគាំទ្រ**

### សំណើរ 4

**លុបចោលការហាមឃាត់លើការផ្តល់មូលនិធិសាធារណៈដល់យុទ្ធនាការបោះឆ្នោត ។ លក្ខន្តិកៈច្បាប់ ។** លុបចោលការហាមឃាត់មិនឱ្យរដ្ឋាភិបាលរដ្ឋ និងរដ្ឋាភិបាលមូលដ្ឋានផ្តល់មូលនិធិសាធារណៈសម្រាប់យុទ្ធនាការបោះឆ្នោតរបស់បេក្ខជន ។ កម្មវិធីផ្តល់មូលនិធិសាធារណៈអាចមិនប្រើប្រាស់មូលនិធិដែលបានកំណត់ទុកសម្រាប់ការអប់រំ ការដឹកជញ្ជូន ឬសុវត្ថិភាពសាធារណៈឡើយ ។ **ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ៖** ថ្លៃចំណាយបន្តរបស់រដ្ឋចំនួនពីរបីសែនដុល្លារក្នុងមួយឆ្នាំ សម្រាប់គណៈកម្មការអនុវត្តន៍ច្បាប់នយោបាយដោយយុត្តិធម៌ ដើម្បីឆ្លើយសំណួរពីរដ្ឋាភិបាលរដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន អំពីកម្មវិធីហិរញ្ញប្បទានយុទ្ធនាការសាធារណៈ ។ **អ្នកគាំទ្រ ៖** League of Women Voters of CA; California Nurses Association; Mental Health Advocacy; Social Security Works; Consumer Watchdog **ភាគីប្រឆាំង ៖** California Taxpayers Assn; Howard Jarvis Taxpayers Assn; Family Business Assn of California; United Latinos Action

- [ ] **គាំទ្រ**
- [ ] **មិនគាំទ្រ**

# សន្លឹកឆ្នោតផ្លូវការ

**ខោនធី SAN JOAQUIN**
**ការបោះឆ្នោតទូទៅ**
**ថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2026**

Khmer BT 77

### សំណើរ 5

**ផ្ទាស់ប្តូរដំណើរការបោះឆ្នោតដកហូតតំណែងសម្រាប់មន្ត្រីទូទាំងរដ្ឋ ។ វិសោធនកម្មច្បាប់រដ្ឋធម្មនុញ្ញ ។** តាមច្បាប់បច្ចុប្បន្ន អ្នកបោះឆ្នោតជ្រើសរើសបេក្ខជនជំនួស ក្នុងពេលតែមួយជាមួយការបោះឆ្នោតដកហូតតំណែង ។ វិធានការនេះជំនួសវិញ នឹងបំពេញតំណែងទំនេរពីការដកហូតតំណែង តាមរយៈការបោះឆ្នោតពិសេសនៅពេលក្រោយ ឬការតែងតាំង ។ **ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ៖** ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុសរុបមិនទាន់ដឹង ។ ក្នុងករណីមានការបោះឆ្នោតដកហូតតំណែង អាចមានការសន្សំថវិកា ឬការចំណាយចំនួនលានដុល្លារ ដើម្បីរៀបចំការបោះឆ្នោត អាស្រ័យលើតំណែងដែលត្រូវបានបោះឆ្នោតដកហូត ។ **អ្នកគាំទ្រ ៖** មិនមានការដាក់ស្នើ**ភាគីប្រឆាំង ៖** មិនមានការដាក់ស្នើ

☐ គាំទ្រ
☐ មិនគាំទ្រ

### សំណើរ 37

**បង្កើតកម្មវិធីកម្ចីសម្រាប់អ្នកទិញផ្ទះថ្មីដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់និងមានប្រាក់ចំណូលមធ្យម ។ លក្ខន្តិកៈផ្តួចផ្តើម ។** អនុញ្ញាតឱ្យចេញមូលបត្របំណុលចំនួន $25 ពាន់លានដើម្បីផ្តល់ប្រាក់កម្ចីទិញផ្ទះក្នុងអត្រាការប្រាក់ថេរដល់អ្នកទិញដែលមានសិទ្ធិសម្រាប់ទឹកប្រាក់រហូតដល់ 17% នៃតម្លៃទិញផ្ទះដែលទើបសាងសង់ថ្មី និងមានតម្លៃក្រោមប្រហែល $1.5 លាន ។ អ្នកខ្ចីត្រូវតែជាអ្នករស់នៅរដ្ឋ California ស្នាក់នៅក្នុងផ្ទះនោះ បំពេញតាមកម្រិតប្រាក់ចំណូលដែលបានកំណត់ និងបង់ប្រាក់កក់យ៉ាងតិច 3% ។ មូលបត្របំណុលត្រូវបានសងតាមរយៈការទូទាត់ប្រាក់កម្ចីទិញផ្ទះ មិនមែនដោយរដ្ឋទេ ។ **ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ៖** មិនមានថ្លៃចំណាយផ្ទាល់របស់រដ្ឋ ឬរដ្ឋាភិបាលមូលដ្ឋានទេ ។ **អ្នកគាំទ្រ ៖** United Nurses Associations of California; California Conference of Carpenters; California State Treasurer Fiona Ma **ភាគីប្រឆាំង ៖** មិនមានការដាក់ស្នើ

☐ គាំទ្រ
☐ មិនគាំទ្រ

### សំណើរ 38

**អនុញ្ញាតឱ្យចេញមូលបត្របំណុលសម្រាប់ការស្រាវជ្រាវវេជ្ជសាស្ត្រផ្នែកភាពស៊ាំវិទ្យា ។ លក្ខន្តិកៈផ្តួចផ្តើម ។** អនុញ្ញាតឱ្យចេញមូលបត្របំណុលកាតព្វកិច្ចទូទៅចំនួន $8.4 ពាន់លានសម្រាប់ការស្រាវជ្រាវផ្នែកភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រើប្រព័ន្ធភាពស៊ាំ ដោយពាក់កណ្តាលផ្តល់ដល់វិទ្យាស្ថានស្រាវជ្រាវវេជ្ជសាស្ត្រមិនរកប្រាក់ចំណេញមួយដែលមានទំនាក់ទំនងជាមួយសាកលវិទ្យាល័យកាលីហ្វ័រញ៉ា និងពាក់កណ្តាលទៀតផ្តល់ជាជំនួយសម្រាប់ការស្រាវជ្រាវ ។ **ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ៖** ថ្លៃចំណាយរបស់រដ្ឋនឹងកើនឡើងពី $500 លានដល់ $600 លាន ក្នុងមួយឆ្នាំ សម្រាប់រយៈពេលប្រហែល 20 ឆ្នាំ ដើម្បីសងមូលបត្របំណុលសម្រាប់ការស្រាវជ្រាវ ដោយការចំណាយមួយផ្នែក ឬទាំងអស់អាចត្រូវបានទូទាត់ប៉ះប៉ូវ ប្រសិនបើការស្រាវជ្រាវដែលទទួលបានមូលនិធិបង្កើតចំណូល ។ **អ្នកគាំទ្រ ៖** Michael J. Fox Foundation; Alzheimer's Los Angeles; Kidney Cancer Assoc; American Nurses Assoc\CA **ភាគីប្រឆាំង ៖** Robert M Kaplan Ph.D.

☐ គាំទ្រ
☐ មិនគាំទ្រ

### សំណើរ 39

**ហាមឃាត់ពលរដ្ឋមិនឱ្យបោះឆ្នោតលុះត្រាតែពួកគេបង្ហាញអត្តសញ្ញាណប័ណ្ណដែលចេញដោយរដ្ឋាភិបាល ។ វិសោធនកម្មរដ្ឋធម្មនុញ្ញ ផ្តើមឡើងដោយប្រជាពលរដ្ឋ ។** ធ្វើឱ្យសន្លឹកឆ្នោតតាមប្រៃសណីយ៍មិនមានសុពលភាព ប្រសិនបើមិនមានលេខបួនខ្ទង់ចុងក្រោយ នៃលេខអត្តសញ្ញាណប័ណ្ណដែលបានកំណត់ និងចេញដោយរដ្ឋាភិបាល សរសេរនៅលើស្រោមសំបុត្រ ។ ហាមឃាត់ការបោះឆ្នោតដោយផ្ទាល់ ប្រសិនបើមិនបង្ហាញអត្តសញ្ញាណប័ណ្ណដែលចេញដោយរដ្ឋាភិបាល ។ **ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ៖** ការអនុវត្តលក្ខខណ្ឌតម្រូវថ្មីសម្រាប់ការបោះឆ្នោតនឹងចំណាយថវិកាចាប់ពី រាប់សិបលានដុល្លារ ដល់រាប់រយលានដុល្លារកម្រិតទាបក្នុងមួយឆ្នាំ ។ **អ្នកគាំទ្រ ៖** The Transparency Foundation; Latino American Political Assn; Howard Jarvis Taxpayers Assn; CA Women's Leadership Assn **ភាគីប្រឆាំង ៖** ACLU California Action; Common Cause; League of Women Voters of California

☐ គាំទ្រ
☐ មិនគាំទ្រ

### សំណើរ 40

**ដាក់ពន្ធតែម្តងលើអ្នកជាប់ពន្ធមួយចំនួន ។ វិសោធនកម្មរដ្ឋធម្មនុញ្ញ និងច្បាប់ ផ្តើមឡើងដោយប្រជាពលរដ្ឋ ។** ដាក់ពន្ធ 5% លើអ្នកជាប់ពន្ធមួយចំនួនដែលមានទ្រព្យសម្បត្តិលើសពី $1 ពាន់លាន ដោយចំណូលពីពន្ធត្រូវប្រើជាចម្បងសម្រាប់ការថែទាំសុខភាព ។ លើកលែងចំណូលទាំងនេះពីលក្ខខណ្ឌតម្រូវតាមរដ្ឋធម្មនុញ្ញស្តីពីការផ្តល់មូលនិធិដល់សាលារៀន និងដែនកំណត់ការចំណាយ ។ **ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ៖** ការកើនឡើងជាបណ្តោះអាសន្ននៃចំណូលចំនួន រាប់សិបពាន់លានដុល្លារ ក្នុងរយៈពេលជាច្រើនឆ្នាំ ពីពន្ធលើទ្រព្យសម្បត្តិរបស់មហាសេដ្ឋី ។ អាចមានការថយចុះជាបន្តបន្ទាប់នៃចំណូលពន្ធលើប្រាក់ចំណូលពីមហាសេដ្ឋីក្នុងចំនួនតិចជាង $1 ពាន់លាន ក្នុងមួយឆ្នាំ ។ **អ្នកគាំទ្រ ៖** US Senator Bernie Sanders; SEIU United Healthcare Workers West **ភាគីប្រឆាំង ៖** California Primary Care Association; California School Boards Association; California Taxpayers Association

☐ គាំទ្រ
☐ មិនគាំទ្រ

### សំណើរ 41

**ហាមឃាត់ពន្ធថ្មីរបស់រដ្ឋ ដែលមិនរាប់បញ្ចូលចំណូលពីពន្ធក្នុងដែនកំណត់ការចំណាយរបស់រដ្ឋ ។ តម្រូវឱ្យមានសវនកម្មសម្រាប់ពន្ធពិសេសថ្មីរបស់រដ្ឋ ។ វិសោធនកម្មរដ្ឋធម្មនុញ្ញ ផ្តើមឡើងដោយប្រជាពលរដ្ឋ ។** ធ្វើឱ្យពន្ធរដ្ឋដែលត្រូវបានអនុម័តក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2026 និងដែលលើកលែងចំណូលពីពន្ធទាំងនោះពីដែនកំណត់ការចំណាយរបស់រដ្ឋដែលបានអនុម័តដោយអ្នកបោះឆ្នោត ក្លាយជាមោឃៈ ។ តម្រូវឱ្យមានសវនកម្មមុនការបោះឆ្នោត និងសវនកម្មជាប្រចាំលើកម្មវិធីដែលទទួលមូលនិធិពីពន្ធពិសេសថ្មី ។ **ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ៖** ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុសុទ្ធមិនទាន់ដឹងនៅឡើយទេ ដោយសារវាអាស្រ័យលើការសម្រេចចិត្តនាពេលអនាគតរបស់អ្នកបោះឆ្នោត ស្ថាប័ននីតិប្បញ្ញត្តិ និងអ្នកកំណត់គោលនយោបាយផ្សេងទៀត ។ **អ្នកគាំទ្រ ៖** CA Society of Certified Public Accountants (CalCPAs); CalAsian Chamber of Commerce; California Taxpayers Association (CalTax) **ភាគីប្រឆាំង ៖** US Senator Bernie Sanders; SEIU United Healthcare Workers West

☐ គាំទ្រ
☐ មិនគាំទ្រ

# សន្លឹកឆ្នោតផ្លូវការ

**ខោនធី SAN JOAQUIN**
**ការបោះឆ្នោតទូទៅ**
**ថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2026**

Khmer BT 77

### សំណើរ 42

**ហាមឃាត់ពន្ធថ្មីរបស់រដ្ឋលើទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងពន្ធរដ្ឋមួយចំនួនដែលមានប្រសិទ្ធភាពប្រតិសកម្ម ។ វិសោធនកម្មរដ្ឋធម្មនុញ្ញ ផ្តើមឡើងដោយប្រជាពលរដ្ឋ ។** ហាមឃាត់ពន្ធថ្មីណាមួយរបស់រដ្ឋដែល (1) ដាក់លើកម្មសិទ្ធិទ្រព្យសម្បត្តិផ្ទាល់ខ្លួន (អ្វីៗទាំងអស់ដែលបុគ្គលកាន់កាប់ ក្រៅពីអចលនទ្រព្យ) ឬ (2) អនុវត្តប្រតិសកម្មដោយផ្អែកលើសកម្មភាពពីមុនរបស់អ្នកជាប់ពន្ធ ។ ធ្វើឱ្យពន្ធដែលត្រូវបានអនុម័តក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2026 ដែលផ្ទុយនឹងវិធានការនេះ ក្លាយជាមោឃៈ ។ **ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ៖** អាចធ្វើឱ្យចំណូលពីពន្ធនៅពេលអនាគតមិនកើនឡើងច្រើនដូចការរំពឹងទុក ។ **អ្នកគាំទ្រ ៖** CA Professional Firefighters; State Building & Construction Trades Council of CA; AMVETS Department of CA **ភាគីប្រឆាំង ៖** US Senator Bernie Sanders; SEIU United Healthcare Workers West

☐ គាំទ្រ
☐ មិនគាំទ្រ

### សំណើរ 43

**កម្រិតសមត្ថភាពរបស់អ្នកបោះឆ្នោតក្នុងការបង្កើនចំណូលសម្រាប់សេវារបស់រដ្ឋាភិបាលមូលដ្ឋាន ។ វិសោធនកម្មច្បាប់រដ្ឋធម្មនុញ្ញ ។** កម្រិតសមត្ថភាពរបស់អ្នកបោះឆ្នោតក្នុងការអនុម័តពន្ធពិសេសមូលដ្ឋានដែលស្នើឡើងដោយអ្នកបោះឆ្នោត ដោយបង្កើនភាគរយនៃសំឡេងឆ្នោតដែលត្រូវការដើម្បីអនុម័តវិធានការបោះឆ្នោតទាំងនោះពីសំឡេងភាគច្រើន (លើសពី 50%) ទៅពីរភាគបី ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2027 ។ **ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ៖** អាចធ្វើឱ្យចំណូលពន្ធរបស់រដ្ឋាភិបាលមូលដ្ឋាននៅពេលអនាគតមិនកើនឡើងច្រើន ដោយសារតម្រូវការកម្រិតសំឡេងឆ្នោតខ្ពស់ជាងមុនសម្រាប់ពន្ធមួយចំនួន ។ **អ្នកគាំទ្រ ៖** California Taxpayers Association; Family Business Association of California; California Hispanic Chambers of Commerce **ភាគីប្រឆាំង ៖** California Professional Firefighters; California Federation of Teachers; Nurse Alliance of SEIU CA.

☐ គាំទ្រ
☐ មិនគាំទ្រ

### សំណើរ 44

**តម្រូវឱ្យគ្លីនិកសុខភាពសហគមន៍ចំណាយ 90% នៃចំណូលលើសេវាកម្មកម្មវិធី ។ លក្ខន្តិកៈផ្តួចផ្តើម ។** ដាក់ទណ្ឌកម្មលើមណ្ឌលសុខភាពមិនរកប្រាក់ចំណេញដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមសហព័ន្ធ (គ្លីនិកសហគមន៍ដែលផ្តល់ការថែទាំសុខភាពបឋមដល់តំបន់ និងប្រជាជនដែលខ្វះខាតសេវាវេជ្ជសាស្ត្រ) ដែលចំណាយតិចជាង 90% នៃចំណូលលើ "សេវាកម្មកម្មវិធី" ដែលជំរុញគោលបំណងសប្បុរសធម៌របស់ពួកគេ រួមទាំងសេវាសម្រាប់អ្នកជំងឺ រួមមានជាអាទិ៍ សេវាសម្រាប់អ្នកជំងឺ ។ **ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ៖** ថ្លៃចំណាយរបស់រដ្ឋកើនឡើងក្នុងចំនួន រាប់សិបលានដុល្លារកម្រិតទាប ក្នុងមួយឆ្នាំ ដែលត្រូវបានរ៉ាប់រងដោយថ្លៃសេវា ។ **អ្នកគាំទ្រ ៖** មិនមានការដាក់ស្នើ**ភាគីប្រឆាំង ៖** American Academy of Pediatrics CA; CA School Nurses Org; CA Academy of Family Physicians; CA Medical Assoc.

☐ គាំទ្រ
☐ មិនគាំទ្រ

### សំណើរ 45

**កែប្រែការត្រួតពិនិត្យផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងមួយចំនួន ។ លក្ខន្តិកៈផ្តួចផ្តើម ។** ធ្វើវិសោធនកម្មច្បាប់គុណភាពបរិស្ថានរដ្ឋ California (CEQA) ដើម្បីពន្លឿនការត្រួតពិនិត្យផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងមួយចំនួន (រួមទាំងគម្រោងលំនៅឋាន ការដឹកជញ្ជូន ទឹក និងសុខភាពភាគច្រើន) ដោយកំណត់ពេលវេលាកំណត់សម្រាប់បញ្ចប់ការត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន និងដោះស្រាយបណ្តឹងតវ៉ាប្រឆាំងនឹងការអនុម័តគម្រោង ។ **ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ៖** ការចំណាយដំបូងសម្រាប់រដ្ឋាភិបាលរដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ទំនងជាមានចំនួន រាប់សិបលានដុល្លារកម្រិតខ្ពស់ ហើយអាចលើសពី $100 លាន ក្នុងមួយឆ្នាំ ដោយមួយផ្នែកត្រូវបានរ៉ាប់រងដោយថ្លៃសេវា ។ ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុរយៈពេលវែងមិនច្បាស់លាស់ ហើយអាចមានផលវិជ្ជមាន ឬអវិជ្ជមានកាន់តែច្រើន ។ **អ្នកគាំទ្រ ៖** California Children's Hospital Association; California Water Association; California Council for Affordable Housing **ភាគីប្រឆាំង ៖** Coalition for Clean Air; CA Environmental Voters; Physicians for Social Responsibility, LA; National Wildlife Federation

☐ គាំទ្រ
☐ មិនគាំទ្រ